# បុព្វយោគ នៃ វិមជ្ឈការ

## ១. អ្វីទៅជាវិមជ្ឈការ ?

វិមជ្ឈការគឺជា ការផ្ទេរអាជ្ញា និង ការទទួលខុសត្រូវសំរាប់មុខងារសារធារណៈពីរដ្ឋាភិបាលថ្នាក់ជាតិទៅរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និង ថ្នាក់មូលដ្ឋាន ឬ ទៅអង្គការស្មើរតែឯករាជ្យនានារបស់រដ្ឋាភិបាល និង ផ្នែកឯកជន ។ នេះគឺជាទស្សនាទានមួយស្មុកស្មាញ និង ដែលមានច្រើនទិដ្ឋភាព ។ បែបវិមជ្ឈការខុសៗគ្នាទាំងឡាយត្រូវតែបានញែកចេញពីគ្នា ដោយហេតុថា វាទាំងឡាយនោះមានចរិតលក្ខណៈ ការផ្តល់ឧបាយអនុវត្តសម្រាប់គោលនយោបាយ និង លក្ខខណ្ឌសម្រាប់ជោគជ័យ ខុសៗគ្នា ។

## ២. វិមជ្ឈការជាអ្វី ?

### បទភ្លេងលេងផ្សំជាមួយនិង សាកលភាវូបនីយកម្ម

វិមជ្ឈការគឺដូចជាបទភ្លេងដែលលេងផ្សំជាមួយ និង សាកលភាវូបនីយកម្ម ។ សាកលភាវូបនីយកម្មជាញយៗដកយកការសម្រេចចិត្តពីឆាកមូលដ្ឋាន និង ជាតិ ទៅដែនសាកលនៃផលប្រយោជន៏ពហុជាតិ និង មិនមែនជាតិ ។ នៅម្ខាងទៀតវិមជ្ឈការនាំយកការធ្វើការសម្រេចចិត្តត្រលប់មកថ្នាក់ក្រោមជាតិ និង ថ្នាក់មូលដ្ឋាន ។ នៅពេលឆ្នៃប្រឌិត យុទ្ធសាស្រ្តវិមជ្ឈការ ចាំបាច់ត្រូវតែមើលទំនាក់ទំនងទៅវិញទៅ មករវាងវិមាត្រផ្សេងៗទាំងឡាយនេះ — សាកល តំបន់ ជាតិ ក្រោមជាតិ មូលដ្ឋាន ។ ទាក់ទង និងរឿងនេះ តួនាទីរបស់រដ្ឋប្រជាជាតិក្លាយទៅជាកាន់តែសំខាន់ថែមទៀត ក្នុងឋានៈជាកម្លាំងដោះស្រាយកណ្តាល រវាងកម្លាំងទាំងឡាយនៃ សាកលភាវបនីយកម្ម ។

### ផ្នែកពេញលេញនៃប្រជាធិបតេយ្យូបនិយកម្ម

វិមជ្ឈការគឺជាផ្នែកពេញលេញនៃតក្កវិជ្ជានៃប្រជាធិបតេយ្យូបនីយកម្ម-អំនាចរបស់ប្រជាជន ដើម្បី កំណត់នូវសណ្ឋាននៃរដ្ឋាភិបាល តំណាង គោលនយោបាយ និង សេវាកម្ម របស់ខ្លួនគេផ្ទាល់ ។ នៅពេលឆ្នៃប្រឌិតយុទ្ធសាស្រ្តវិមជ្ឈការ គឺសំខាន់ណាស់ដែលត្រូវតែធ្វើឱ្យប្រាកដថាដំនើរការទាំងឡាយ មានសមល្មមក្នុងវិស័យទទួលខុសត្រូវតម្លាភាព នឹងភាពឆ្លើយតបដោយតួអង្គរបស់សង្គមទាំងអស់ ។

### បាតុភូតមួយពាក់ព័ន្ធ និង តំបន់ តួអង្គ និង ផ្នែកច្រើន

វិមជ្ឈការគឺជាបាតុភូតមួយស្មុកស្មាញពាក់ព័ន្ធ និង អង្គភាពភូមិសាស្ត្រច្រើនតួអង្គ និង ផ្នែកច្រើន របស់សង្គម ។ អង្គភាពភូមិសាស្ត្រមានរាប់បញ្ចូលទាំងអន្តរជាតិ ជាតិ ក្រោមជាតិនិង មូលដ្ឋាន ។ តួអង្គ របស់សង្គម មានរាប់បញ្ចូល ទាំងរដ្ឋាភិបាល ផ្នែកឯកជន និងសង្គមស៊ីវិលផងដែរ ។ ផ្នែកសង្គមមាន រាប់បញ្ចូលទាំងប្រធានបទទាំងអស់នៃអភិវឌ្ឍន៏នយោបាយ សង្គម វប្បធម៌ និង បរិស្ថាន ។ ក្នុងការច្នៃប្រឌិត គោលនយោបាយ និង កម្មវិធីទាំងឡាយនៃវិមជ្ឈការគឺសំខាន់ណាស់ដែលត្រូវប្រើមិតាប្រព័ន្ធដែលមានរួម បញ្ចូលនូវផ្នែកសង្គមទាំងឡាយដែលគ្របលើគ្នា ព្រមទាំងតម្រូវការផ្សេងៗគ្នាដែលផ្នែកនិមួយៗទាមទា ។

## ការអនុវត្តសមតាមតក្កវិជ្ជា នៃ ចរិតលក្ខណៈស្នូលនៃអភិបាលកិច្ចល្អ

វិមជ្ឈការគឺជា "ការអនុវត្តសមតាមតក្កវិជ្ជា នៃ ចរិតលក្ខណៈស្នូលនៃអភិបាលកិច្ចល្អ"នៅថ្នាក់ក្រោមជាតិ និង មូលដ្ឋានទាំងឡាយ ។ ចរិតលក្ខណៈទាំងឡាយនេះរួមមានការទទួលខុសត្រូវ តម្លាភាព អាជ្ញានៃច្បាប់ ហើយនិង ភាពនៃការឆ្លើយតប ។ ក្នុងការច្នៃប្រឌិតគោលការនយោបាយ និង កម្មវិធីទាំង ឡាយនៃ វិមជ្ឈការ ចរិកលក្ខណៈស្នូលនៃអភិបាលកិច្ចល្អ ផ្តល់នូវសុំណុំនៃគោលការណ៏ណែនាំសមល្អដល់ ការប្រតិបត្តិនូវគោលទាំងឡាយនេះ ។

## ល្បាយមួយនៃមុខងារ នឹងទំនាក់ទំនងបីយ៉ាង

វិមជ្ឈការជា ល្បាយមួយនៃមុខងារនិងទំនាក់ទំនងរដ្ឋបាល ហិរញ្ញវត្ថុ និង នយោបាយ ។ ក្នុងការច្នៃប្រឌិត ប្រព័ន្ធវិមជ្ឈការ ទាំងបីនេះត្រូវតែមានរួមបញ្ចូល ។

## ល្បាយបួនវិមាត្រមួយ

វិមជ្ឈការទាក់ទិននិង បួនវិមាត្រ-សមូហៈ/ក្រៅ សមូហៈ/ក្នុង និងឯកត្តជន/ក្រៅ ឯកត្តជន/ក្នុង ។ សមូហៈភាព/ក្រៅទក់ទងជាមួយ និង ទម្រង់ស្ថាប័ន និងច្បាប់ និង បែបបទទាំងឡាយ ។ សមូហៈ/ក្នុង និងស្តីអំពី វប្បធមិរបស់សង្គម-សំណុំគុណតម្លៃសេចក្តីសម្ចត់ទាំងឡាយ ដែលជាញយៗ មិនត្រូវបានចេញ ជាសំដី ឬទទួលស្គាល់ឡើយ ក៏ប៉ុន្តែមានតួនាទីដ៏អង់អាចក្នុងទំទាក់ទំនងទាំងឡាយរបស់មនុស្ស ។ វិមាត្រ ឯកត្តជន/ក្រៅទាក់ទងជាមួយឥរិយាបទដែលអាចសង្កេតបានរបស់ឯកត្តជនទាំងឡាយនៅក្នុងស្ថាប័ន ផ្សេងៗរបស់សង្គម ទោះបីជារដ្ឋាភិបាល ផ្នែកឯកជក ឬ សង្គមស៊ីវិលក៏ដោយ ។ វិមាត្រឯកត្តជន/ក្នុង ស្តីអំពីផ្នត់ចិត្តគំនិត ទស្សន គំរូក្នុងចិត្ត ការរំជួលចិត្ត អព្ភន្តរញ្ញាណរបស់ឯកត្តជន នៅក្នុងស្ថាប័នទាំងឡាយ ។ ការធ្វើទំរង់វិមជ្ឈភិបាលកិច្ចដែលប្រកបដោយប្រសិទ្ធិភាពចាំបាច់ត្រូវតែឈរលើមូលដ្ឋាន នៃការវិភាគ នៃវិមាត្រទាំងបួននេះ ។

## សណ្ឋានមួយនៃការប្រាស្រ័យទាក់ទង ( គមនាគមន៏ ) ថ្មី

វិមជ្ឈការទាក់ទិននិងការប្រាស្រ័យទាក់ទងនិងលំហូរនៃ ពត៌មានថ្មីរវាងតំបន់ភូមិសាស្ត្រទាំងឡាយ តួអង្គរបស់សង្គមនិងផ្នែករបស់សង្គម ។ ថ្នាក់ស្រុកជាញយៗគឺជាប្លាតហ្វម មានប្រយោជន៏សម្រាប់ ការមកជួបជុំគ្នា នៃតួអង្គជាតិនិងមូលដ្ឋានទាំងឡាយ ដើម្បីសន្ទនាធ្វើការសម្រេចចិត្ត រៀបចំថវិការ និង របាយការណ៏ (Work, 1998) ។

## ៣. វិមជ្ឈការមិនមែនជាអ្វី ?

### ជំរើសផ្តាច់គ្នាជាមួយ និង មជ្ឈការ

វិមជ្ឈការមិនមែនជាជំរើសផ្តាច់គ្នាជាមួយ និង មជ្ឈការទេ ។ ទាំងពីរត្រូវការចាំបាច់ ។ តួនាទីបំពេញបង្គ្រប់ របស់តួអង្គថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ត្រូវតែបានកំណត់ដោយការវិភាគរកផ្លូវ និងមធ្យោបាយ ទាំងឡាយដែលមានប្រសិទ្ធិភាព បំផុតដើម្បីសម្រេចបាននូវវត្ថុបំនងដែលចង់បានណាមួយ ។ ជាឧទាហរណ៏ ប្រព័ន្ធផ្តល់ជាតិត្រូវតែបានច្នៃប្រឌិត ឡើងដោយមានរួមទាំងចំណូលពីមូលដ្ឋាន និង ការសម្រប់សម្រួល ថ្នាក់ជាតិ។ គោលនយោបាយក្រៅប្រទេសត្រូវតែជាមុខងារជាតិដែលឈរ លើមូលដ្ឋាននៃទស្សន របស់ ពលរដ្ឋ ។ ការគ្រប់គ្រងកាកសំណល់រឹង ជាបឋមត្រូវតែដោះស្រាយ តាមរយៈយន្តការនៅមូលដ្ឋាន ។ល។ និង ។ល។ ក្នុងពេលឆ្នៃប្រឌិតយុទ្ធសាស្ត្រវិមជ្ឈការគឺដាច់ខាត ត្រូវតែធ្វើការវិភាគបែបនេះ។

### ការកែទម្រង់ដែលមានផ្តាច់មុខតែក្នុងផ្នែកសាធារណៈ

វិមជ្ឈការគឺច្រើនលើសអំពើការកែទម្រង់ផ្នែកសាធារណៈសេវាស៊ីវិល និង រដ្ឋបាល ។ វាទាក់ទងនិងតួនាទីនិងទំនាក់ទំនងទាំងឡាយរបស់តួអង្គទាំងអស់របស់សង្គម មិនថារដ្ឋាភិបាលផ្នែកឯកជន ឬសង្គមស៊ីវិលនោះឡើយ ។ ការច្នៃប្រឌិតកម្មវិធីវិមជ្ឈការត្រូវតែយកបញ្ហានេះមកគិតគូរផង ។ ហេតុនេះហើយបានជា UNDP ចូលចិត្តវាក្យសព្ទ "វិមជ្ឈភិបាលជាងវិមជ្ឈការ" ។

## ៤. ហេតុអ្វីបានជាធ្វើវិមជ្ឈការ ?

### ដើម្បីបានសម្រេចនូវគោលបំនងទាំងឡាយនៃការអភិវឌ្ឍប្រកបដោយចិរភាព និង ដែលមានមជ្ឈដ្ឋានក្នុងប្រជាជន។

វិមជ្ឈការជាសណ្ឋាន និង ជាដំនើរការនៃអភិបាលកិច្ច។ ដោយហេតុ ថាអាចមានអភិបាលកិច្ចល្អនៅថ្នាក់ជាតិនោះក៏អាចមានវិមជ្ឈភិបាលកិច្ចល្អដូចគ្នាដែរ ។ អភិបាលកិច្ចល្អរួមមានយន្តការ

និងតំនើរការទាំងឡាយ ដែលផ្តល់លទ្ធភាពអោយសង្គមមួយអាច សម្រេចបាននូវការអភិវឌ្ឍ ដែលកាន់តែមានចិរភាព និង មានមជ្ឈដ្ឋានក្នុងប្រជាជនល្អទៅទៀត ។ វិមជ្ឈភិបាលល្អរួមមាន សណ្ឋាន និង បែបបទទាំងឡាយដែលជួយអោយសង្គមមួយសម្រេចបាននូវ គោលបំនងទាំងឡាយ ថ្នាក់រក្រោមជាតិ និង មូលដ្ឋាន នៃការកាត់បន្ថយភាពក្រីក្រ អាជីពប្រកប ដោយចិរភាពទធ្វើឱ្យ បរិស្ថានកើតឡើងវិញ និង សមភាពយែនឌ័រ ។ ដូច្នេះចាំបាច់ក្នុងការច្នៃប្រឌិត គោលនយោបាយ នៃវិមជ្ឈភិបាល និង កម្មវិធីទាំងឡាយ គោលបំនងរយៈពេលវែងទាំងឡាយនេះ ត្រូវតែបាន ឆ្លុះបញ្ចាំងក្នុងយុទ្ធការ និង សាប័នទាំងឡាយដែលត្រូវបានស្នើរឡើងនៅថ្នាក់ជាតិ ក្រោមជាតិ និង មូលដ្ឋាន ។ គឺមិនអាចនិងត្រូវបានសន្មត់ទុកថា គោលបំនងទាំងឡាយនេះ និង ត្រូវបានសម្រេច ជាស្វ័យប្រវត្តតាមរយៈវិមជ្ឈការនោះទេ ។ គោលបំនងទាំងឡាយនេះគឺត្រូវតែ បានឆ្នៃប្រឌិត បញ្ចូលទៅក្នុងដំនើរការវិមជ្ឈការខ្លួនឯងតែម្តង ។

## ទស្សនៈចំនួន២ អំពីវិមជ្ឈការ

| ទស្សនៈគាំទ្រវិមជ្ឈការ | ទស្សនៈនៅសង្ស័យចំពោះវិមជ្ឈការ |
|---|---|
| ▪"ការបោះឆ្នោតត្រឹមត្រូវនិងសេរី ហើយប្រព័ន្ធនយោបាយប្រកួតប្រជែង នៅមូលដ្ឋាន និង ផុះចេញឡើង " | ▪" លក្ខខណ្ឌអភិបាលកិច្ច គឺធ្វើយ៉ាង ណាដែលនិងបង្កើតស្រទាប់មួយទៀត ដែលមិនសក្តិសិទ្ធរបស់រដ្ឋ " |
| ▪" ធនធានទាំងឡាយ និង ត្រូវបានដាក់ឱ្យប្រើប្រាស់ពីថ្នាក់ជាតិ ឬ ដោយការទារព័ន្ធនៅមូលដ្ឋាន " | ▪"វិមជ្ឈការជាតំនើរការថ្លៃពេក "(ដោយ មានរាប់បញ្ចូលទាំងហានិភ័យ នៃការខ្វះ វិន័យផ្នែកហិរញ្ញវត្ថុ) ដូច្នេះ ប្រទេស ជាច្រើន (ជាពិសេសប្រទេស តូចតាច) មិនអាចមាន សោហ៊ុយធ្វើកើតទេ " |
| ▪"ការធ្វើសេចក្តីសម្រេចចិត្តអំពីផែន ការ និង អាទិភាពនូវមូលដ្ឋាន និងធ្វើឡើងនៅថ្នាក់មូលដ្ឋាន មិនមែននៅថ្នាក់ជាតិទេ " | ▪"វិមជ្ឈការមិនអាចធ្វើទៅបានមុនពេល ដែលមានសមត្ថភាពជាចាំបាច់នៅថ្នាក់ជាតិ" |
| ▪"ប្រព័ន្ធប្រជាធិបតេយ្យថ្មីនៅមូល ដ្ឋានអាចប្រឈមមុខនិងប្រភពអាជ្ញា ជាជំរើសឆ្លាស់ (ប្រពៃណីបាន)" | ▪"វិមជ្ឈការ និង នាំទៅរកការប៉ះទង្គិចគ្នា រវាងប្រភពទាំងឡាយនៃអជ្ញា និង អជ្ញាស្របច្បាប់ " |
| ▪"ពលរដ្ឋនិងមានលទ្ធភាពប្រើប្រាស់ សម្លេងរបស់ខ្លួនក្នុងការគ្រប់គ្រងកិច្ច ការមូលដ្ឋាន " | ▪" គ្មានមូលធនសង្គមគ្រប់គ្រាន់នៅថ្នាក់ មូលដ្ឋានសម្រាប់លើកកំពស់ការចូលរួមប្រកប ដោយប្រសិទ្ធភាព ក្នុងកិច្ចការមូលដ្ឋាន " |
| ▪" ធ្វើវិមជ្ឈការក្នុងការចែកចាយផ្តល់ សេវា នាំទៅរកលទ្ធផលកាន់តែល្អ ប្រសើរដែលធ្វើឱ្យប្រជាជនក្រីក្រចំនេញ" ។ | ▪"វិមជ្ឈការមានផលប៉ះពាល់មិនដាក់ ទៅលើការកាត់បន្ថយភាពក្រីក្រ " ។ |

## ៥. ធ្វើវិមជ្ឈការយ៉ាងដូចម្តេច ?

### ពិនិត្យមើល "DNA" នៃវប្បធម៌ដែលមានស្រាប់

វិមជ្ឈការគឺមានផល់ប៉ះពាល់ដោយ "DNA" នៃវប្បធម៌របស់សង្គម-រូបភាពក្នុងចិត្ត សេចក្តីសន្មត់និង រឿងនិទានខាងក្នុងទាំងឡាយដែលប្រជាជនធ្វើប្រតិបត្តិការស្វែងទាក់ទងនិង បញ្ហាអាជ្ញា តួនាទីរបស់

រដ្ឋាភិបាលតួនាទីរបស់ពលរដ្ឋ ទំនាស់ កុងសង់ស៊ុសស្រុះស្រួល តួនាទីរបស់វីរៈជនតួនាទីរបស់អ្នកក្រីក្រ តួនាទីរបស់ស្ត្រី តួនាទីរបស់មូលធន ។ល ។ ដើម្បីច្នៃប្រឌិតយុទ្ធសាស្ត្រ និង យន្តការនៃវិមជ្ឈការឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវវិភាគ "DNA" នៃវប្បធម៌ដែលទ្រទ្រង់នៅពីក្រោមហើយបំផុសឱ្យចេញជា ឥរិយាបថ និង ទំនាក់ទំនងជាក់ស្តែងទាក់ទិនជាផលវិបាក ។

## ពិនិត្យមើលទំនាក់ទំនងទាំងឡាយដែលប្រែប្រួល

វិមជ្ឈការទាក់ទិនជានិច្ចជាមួយ និង ការផ្លាស់ប្តូរទាំងឡាយនៃទំនាក់ទំនងរវាង និង ក្នុងចំណោមតួអង្គនៃសង្គម ផ្នែកសង្គម និង តំបន់ភូមិសាស្ត្រផ្សេងៗ ។ ការផ្លាស់ប្តូរទាំងឡាយនេះអាចគំរាម ឬត្រូវមើលឃើញថាអាចផ្តល់នូវលទ្ធភាពជួយដល់ក្រុមទាំងអស់ ... ស្ថានភាពឈ្នះៗ ។ ក្នុងការច្នៃប្រឌិតយុទ្ធសាស្ត្រវិមជ្ឈការចាំបាច់ត្រូវគិតឱ្យចប់ចុងចប់ដើមអំពីម៉ាតាដែលមានប្រសិទ្ធភាពជាងគេដើម្បីធ្វើការផ្លាស់ប្តូរទំនាក់ទំនងអំណាច អាជ្ញា និង ការទទួលខុសត្រូវ ឈរលើមូលដ្ឋាននៃការជំរុញទឹកចិត្ត និង ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ក្រុមនានាដែលទាក់ទិន ព្រមទាំងវត្ថុបំណងរួមដែលចែករំលែកគ្នា ដោយក្រុមទាំងអស់ និង ឯកត្តជន ។ ចាំបាច់ត្រូវតែបង្អាច និង កសាងសមត្ថភាពនៃតួអង្គទន់ខ្សោយ និង ផ្តល់ នូវគ្រឿងទាក់ទងចិត្តសម្រាប់ឱ្យក្រុមនិមួយៗធ្វើការផ្លាស់ប្តូរដែលចង់បាន ។

## ពិនិត្យមើលការកំនត់ពេលវេលា និង ការរៀបលំដាប់

វិមជ្ឈការ គឺជាការខំប្រឹងប្រែងរយៈពេលវែង ដែលនៅក្នុងនោះការកំនត់ពេល និង ជំនាក់ការមានសារៈសំខាន់ណាស់ ។ ក្នុងការច្នៃប្រឌិត និង អនុវត្តត្រូវតែបានទទួលការអនុមត្ត ប្រសើជាង " ប្រព្រឹត្តិកម្មដោយប៉ះទង្គិចគ្នា " ។ ទោះជាយ៉ាងនោះក៏ដោយក៏គ្មានរូបមន្តផ្សំជាសកលណាមួយដើម្បី រៀបចំលំដាប់បន្តបន្ទាប់សម្រាប់វិមជ្ឈការឡើយ ។

## ពិនិត្យមើលលើគុណភាពយន្តការសម្រាប់ការចូលរួម និង ភាពជាដៃគូ

ប្រសិទ្ធភាពនៃវិមជ្ឈការ អាចត្រូវបានបង្កើនតាមរយៈយន្តការទាំងឡាយនៃការចូលរួមពេញលេញ និង ភាពជាដៃគូ ។ ការចូលរួមត្រូវតែទាក់ទិន និង តួអង្គទាំងអស់របស់សង្គម បានសម្តែងតួនាទីធំបុត និង ស្របច្បាប់នៅក្នុងការរៀបចំតាក់តែងគោលនយោបាយ ការគ្រប់គ្រងធនធាន និង ការផ្តល់សេវា ។ ការចូលរួមរបស់ប្រជាជន គឺសំខាន់ណាស់នៅគ្រប់ដំណាក់ការនៃវិមជ្ឈការ ចាប់ពីការវិភាគស្ថានភាព ការច្នៃប្រឌិត ការអនុវត្ត ការតាមដាន ការវាយតម្លៃ និង ក្រផ្តល់ព័តមានត្រលប់មកវិញ ។ ភាពជាដៃគូ ត្រូវតែឈរលើមូលដ្ឋាននៃការទុកចិត្តគ្នាទៅវិញទៅមក ការយល់ដឹងរបស់តួអង្គនានា ទទួលដឹងថាម្នាក់ៗ មានផ្នែកខ្លាំង និងផ្នែកខ្សោយ ។ តួអង្គនិមួយៗត្រូវតែផ្តល់នូវលទ្ធភាពជូនតួអង្គដ៏ទៃទៀត នៅក្នុងតួនាទី ស្របច្បាប់របស់គេផង ហើយ

ប្រកាន់ទុកថា គេជាប់ជំពាក់គណនី នៅពេលដែលគេកន្លងអាណត្តិស្រប ច្បាប់របស់គេ ។ គឺសំខាន់ណាស់ ដែលត្រូវតែជ្រើសរើសច្រកចូលទាំងឡាយសំរាប់ភាពជាដៃគូ ដែលនិង បណ្តោយឱ្យមានការប្រឹងប្រែង ជាសហការគ្នាក្នុងចំណោមតួអង្គផ្សេងៗ ។ ហិរញ្ញប្បទាន ត្រូវតែដាក់ឱ្យ មានប្រើប្រាស់បានសម្រាប់ មីក្រូគម្រោងទាក់ទង និង ទង្វើសហការគ្នា ។ ការច្នៃប្រឌិត ការប្រឹងប្រែង ធ្វើវិមជ្ឈការត្រូវតែ លើកកំពស់ការកកើត ទាំងការចូលរួមទាំងភាពជាដៃគូ ។

### ពិនិត្យមើលគំរូនៅក្នុងចិត្តដែលកំពង់ប្រើ

វិមជ្ឈការជាវាក្យសព្ទដែលបានមកពីគំគូក្នុងចិត្តដែលមានមជ្ឈមណ្ឌល និង បរិមណ្ឌល ។ នេះគឺគ្រាន់តែជាគំរូ ដូចគ្នា និង សាជីជ្រុងនៃរចនាសម្ព័ន្ធសង្គមជាគំរូនៅក្នុងចិត្តតែប៉ុណ្ណោះ ។ ពេលនោះ យើង មើលទៅសង្គមជាប្រព័ន្ធទាំងមូលយើងមិនឃើញនូវស្រទាប់ៗ (ដូចដែលនូវក្នុងសាជីជ្រុង ) ពីលើទៅក្រោម ឬ ស្រទាប់ៗដែលមានមជ្ឈមណ្ឌលជាមួយគ្នា (ដូចនៅក្នុងគំរូបែបមជ្ឈមណ្ឌល ) ប៉ុន្តែជាទីលានផ្តេក សម្រាប់ល្បែងព្រមជាមួយ និង តួអង្គផ្នែក និង តំបន់ភូមិសាស្ត្រទាំងឡាយ ស្វ័យត្តតែទាក់ទងគ្នា ទៅវិញទៅមក ។ ទស្សនវិទូ ហាបស៍ បានផ្តល់មកយើងនូវគំរូក្នុងចិត្តមួយទៀតនៃសង្គម ...គឺអង្គកាយ មនុស្ស ។ ក្នុងការច្នៃប្រឌិតគោលនយោបាយ និង កម្មវិធី វិមជ្ឈការចាំបាច់ត្រូវតែដឹងអំពីខ្លួនឯងអំពីគំរូ ក្នុងចិត្តដែលខ្លួនយកមកប្រើហើយបើចាំបាច់ត្រូវតែយកលំនាំតាម ឬ ផ្លាស់ប្តូរាគំរូទាំងស្រុងដើម្បីតម្រូវ និង ភាពពិត " Work ,1998 " ។

## ៦. តើហានិភ័យនៃវិមជ្ឈការមានអ្វីខ្លះ ?

### សមភាវូបនីយកម្មហិរញ្ញវត្ថុ :

ហានិភ័យមួយក្នុងចំនោមហានិភ័យធំៗនៃវិមជ្ឈការគឺហានិភ័យនៃកំនើនវិសមភាពតាមរយៈ វិមជ្ឈការវិស័យហិរញ្ញវត្ថុដែលគ្មានតុល្យភាពទូទាំប្រទេស ។ ស្រុកតំបន់ ឬ ទីកន្លែងខ្លះៗដែលមាន អំណោយទាន ស្រាប់អាចគ្រាន់បើជាងស្រុក និង តំបន់ក្រីក្រ ដូច្នេះរង់ចាំតែទទួលនូវចំនេញថែមទៀតពី ដំនើរការ វិមជ្ឈការវិស័យហិរញ្ញវត្ថុដែលគ្មានតុល្យភាព ។ នេះមានន័យថា នៅពេលណាដែលមានភាព ខុសគ្នា គួរឱ្យកត់សំគាល់នៃអំណោយទានធនធាន ក្នុងបណ្តាដែនសមត្ថកិច្ចជាភាគផ្សំ នៃ ប្រទេសមួយនោះ វិធានការសមភាវូបនីយកម្មត្រូវតែបានចាត់ឡើង ដើម្បីបញ្ចៀសនូវសក្កានុភូតដែលមានមិនដែលខាន នៃវិមជ្ឈការវិស័យហិរញ្ញវត្ថុបង្កឡើងមិនចប់មិនហើយ នូវភាពខុសគ្នាកាន់តែធំដោយការអភិវឌ្ឍ ។

ប្រទេសមួយចំនួនបានទទួលស្គាល់ការពិនិត្យមើល និង រូបមន្តសមភាវូបនីយកម្មដ៏សំខាន់នេះហើយ បានរួមបញ្ចូលការអនុវត្តនៃការផ្ទេរហិរញ្ញវត្ថុដោយរើសអើងដោយផ្អែកលើ ទ្រង់ទ្រាយមុខនៃភាព ក្រីក្ររបស់តំបន់ទីក្រុងទាំងឡាយជាអ្នកទទួល ។ អ្វីដែលសំខាន់ដើម្បីសង្កេត គឺថាមានគោលការណ៍ សម្រាប់ណែនាំជាច្រើនសម្រាប់ការរៀបចំចំតាក់តែងសមភាវូបនីយកម្មហិរញ្ញវត្ថុ ហើយថាជំរើស នៃអ្វីដែលត្រូវយកមកពិនិត្យមើលត្រូវតែឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៅ និង កន្លែង ។

### វិវជននៅនិងកន្លែង

មានហានិភ័យ ដែលវិមជ្ឈការអាចជួយធ្វើឱ្យរចនាសម្ព័ន្ធនៃវិវជននៅនិងកន្លែងអាចកាន់តែរឹង មាំឡើងៗ ហើយដែលវិវជននៅនិងកន្លែងអាចចាប់បាននូវដំណើរការវិមជ្ឈការដ៏ក្មេងយខ្ចីមួយ ។ ច្បាស់ ហើយ នេះគ្រាន់តែពង្រឹងដល់ការចាំបាច់ ត្រូវការធ្វើការជាមួយ និង ទិដ្ឋភាពទាំងពីរនៃវិមជ្ឈការ និង អភិបាលកិច្ចមូលដ្ឋាននៅពេលដែលខំខ្នះខ្នែងធ្វើឱ្យប្រជាធិបតេយ្យ និង ដំនើរការ នយោបាយនូវមូលដ្ឋានឱ្យកាន់តែប្រសើរឡើង។ តម្រូវការអោយមានសង្គមស៊ីវិលមួយស្វាហាប់ក៏ត្រូវបានសង្កត់ ផងដែរនៅ ពេលនេះ ។

### ការប្តេជ្ញាចិត្តនយោបាយ :

គឺត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាការប្តេជ្ញានយោបាយ ពីសំណាក់រដ្ឋាភិបាលសហព័ន្ធ និង រដ្ឋគឺជាលក្ខខណ្ឌខានពុំបាននៃវិមជ្ឈការតាមបែបប្រជាធិបតេយ្យដែលប្រកបដោយប្រសិទ្ធភាពហើយជាពិសេសនៃសណ្ឋាននៃវិមជ្ឈការតែត្រូវបានផ្គុំឡើងដើម្បីផលប្រយោជន៍នៃអ្នកក្រីក្រ ។ វិមជ្ឈការជួយអ្នក ក្រីក្រដែលមានជោគជ័យ គឺទាក់ទងជាប់សនិត និង គណបក្សគ្រប់គ្រងដែលប្តេជ្ញាតាមផ្លូវនយោបាយចំពោះការបង្ហាញរសបៀបប្រជាធិបតេយ្យនៃរដ្ឋាភិបាលមូលដ្ឋានទាំងឡាយ ។ យ៉ាងណាក៏ដោយគឺសំខាន់ណាស់ដែលត្រូវពិនិត្យមើលនូវវិសាលគមន៍ទូលាយនៃបញ្ហាដែលមានឥទ្ធិពលលើវិមជ្ឈការ។ មានការចាំបាច់ ត្រូវផ្តោតទៅលើបញ្ហាស្ថាប័ន គឺថាទាំងទៅលើនិយាមទាំងឡាយដែលមានឥទ្ធិពលដល់តរិយាបទ របស់តួអង្គទាំងឡាយ នៅថ្នាក់ផ្សេងៗរបស់រដ្ឋាភិបាលនៅក្នុងផ្នែកឯកជន និង សង្គមស៊ីវិល ទាំងទៅលើ អង្គការទាំងឡាយដែលអនុវត្តនិយាមទាំងឡាយនេះ ។ ាំងឡាយនេះគឺត្រូវបានក្លាយទៅជាស្តែងៗ ទៅហើយ ។ របៀបវារៈទូលាយបែបនេះបាននាំទៅដល់នូវការផ្តោតដែលមានគុណភាពកាន់តែល្អឡើង ទៅលើគណនីភាព (ការទទួលខុសត្រូវ ) មានការផ្តល់ឧបាយអនុវត្តខ្លាំងសំរាប់ច្នៃប្រឌិតគម្រោង និង ធ្វើការសន្ទនាអំពីគោលនយោបាយ ហើយទាមទាឱ្យមានការប្រឹងប្រែងស្រាវជ្រាវកាន់តែស្វាហាប់ដែលផ្តោតទៅលើប្រទេសកំពុងអភិវឌ្ឍ ។

### ការប្តេជ្ញាចិត្តរយៈពេលវែងនៃម្ចាស់ជំនួយ :

បើការអភិវឌ្ឍនៃប្រព័ន្ធអភិបាលមូលដ្ឋានដែលបានការត្រូវបានជាកិច្ចការមួយជាអាទិភាព នោះគឺ អាច សន្និដ្ឋានសមតាមតក្កវិជ្ជាថាគោលនយោបាយវិមជ្ឈការទាំងឡាយរបស់ភ្នាក់ងារនៃម្ចាស់ជំនួយទាមទា ឱ្យមានចក្ខុវិស័យបែបស្ថាប័នរយៈពេលវែង ។ នេះគឺបណ្តាលមកហេតុការណ៍ដែលថាដំនើរការ នៃវិមជ្ឈការ គឺមាន ទិដ្ឋភាពនយោបាយខ្ពស់ណាស់ ផុយស្រួយ និង ប្រកបដោយហានិភ័យ ហើយតម្រូវ ការឱ្យមានទស្សន ផ្នែកស្ថាបនគឺសំខាន់ណាស់ (Olsen, 2007 ) ។

## ៧. តើមានវិមជ្ឈការប៉ុន្មានយ៉ាង ?

ដោយខ្លីវិមជ្ឈការក្នុងផ្នែកសាធារណៈ មានបីយ៉ាង :

១. វិមជ្ឈការនយោបាយ គឺជាការផ្ទេរអំណាចនយោបាយ និង អាជ្ញាធ្វើការសម្រេចចិត្ត ទៅថ្នាក់ក្រោមជាតិទាំងឡាយដូចជាក្រុមប្រឹក្សាភូមិ ស្រុក និង អង្គការថ្នាក់រដ្ឋដែលបានជាប់ឆ្នោត ។ នៅទីណាមានការផ្ទេរបែបនោះធ្វើឡើងឱ្យទៅថ្នាក់មូលដ្ឋានមួយនៃអាជ្ញាសាធារណៈដែលជាស្វ័យ័ត និង ឯករាជ្យពេញលេញណពីអាជ្ញាដែលផ្ទេរអំណាចមកក្រោម នោះការផ្ទេរអំណាចមកក្រោមបាន ប្រព្រឹត្តទៅ ។

២. វិមជ្ឈការហិរញ្ញវត្ថុ ទាក់ទិន និង ការបែងចែកធនធានឡើងវិញទៅរដ្ឋាភិបាលមូលដ្ឋាន ដែលនិង អនុញ្ញាតឱ្យគេបំពេញមុខងារបានត្រឹមត្រូវនិងការទទួលខុសត្រូវលើសេវាផ្តល់មូលនិធិដែលត្រូវបានចែកចាយ ដោយមានការរៀបចំសម្រាប់ការចែកចាយធនធាន ជាធម្មតា ត្រូវបានចរចារវាងអាជ្ញាធរ មូលដ្ឋាន និង ថ្នាក់ជាតិ ។ គោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ តាមធម្មតាត្រូវលើកយកមកដោះ ស្រាយនូវបញ្ហាដូចជា ការដាក់កំណត់ពន្ធ និង ការចែករំលែកប្រាក់ចំនូលនៅមូលដ្ឋានតាមរយៈ ការដាក់ពន្ធ និង អាករអ្នកប្រើ និង ទីផ្សារ ។

៣. វិមជ្ឈការរដ្ឋបាល ទាក់ទិន និង ការផ្ទេរអាជ្ញាធ្វើការសម្រេចចិត្ត ធនធាន និង ការទទួលខុសត្រូវសម្រាប់ការផ្តល់សេវាសាធារណៈជំរើសខ្លះៗ ពីរដ្ឋាភិបាលថ្នាក់ជាតិ ទៅថ្នាក់ទាប់ៗរបស់រដ្ឋាភិបាល ភ្នាក់ងារ និង ការិយាល័យនៅទីប្រតិបត្តការរបស់ភ្នាក់ងារបច្ចេក ទេសរបស់រដ្ឋាភិបាលថ្នាក់ជាតិ ។ សណ្ឋាននៃកំណែទម្រង់នៃវិមជ្ឈការរដ្ឋបាលដែលជ្រៅដល់ឬសជាង គឺការផ្ទេរអំណាចដោយមានរដ្ឋាភិបាលមូលដ្ឋានទទួលខុសត្រូវពេញលេញក្នុងការជួល/ដេញចោល បុគ្គលិក និង ការប្រគល់អាជ្ញាដែលការទទួលខុសត្រូវ។ សហវិមជ្ឈការ គឺជាការផ្ទេរអាជ្ញា និង ការទទួលខុសត្រូវពីរថ្នាក់មួយនៃរដ្ឋាភិបាលថ្នាក់ជាតិ ទៅថ្នាក់មួយទៀតដោយមានអង្គភាព




មូលដ្ឋានជំពាក់គណនីយភាព និង ក្រសួង ឬ ភ្នាក់ងាររបស់រដ្ឋាភិបាលថ្នាក់ជាតិ ដែលត្រូវបានទទួលអនុវត្តវិមជ្ឈការ ។ ប្រតិភូកម្ម ម៉្យាងទៀត គឺជាការចែកអាជ្ញា និង ការទទួលខុសត្រូវឡើងវិញទៅ

អង្គភាពមូលដ្ឋានរបស់រដ្ឋាភិបាល ឬ ភ្នាក់ងារទាំងឡាយដែលមិនចាំបាច់តែជាសាខា ឬ ការិយាល័យនៅមូលដ្ឋានរបស់អាជ្ញាធរដែលធ្វើប្រតិភូកម្មនោះ ដោយមានទំងន់ធំនៃគណនីយភាព ( ការ ទទួលខុសត្រូវ ) តម្រង់ទិសទៅលើតាមខ្សែបន្ទាត់ឈរទៅរកអង្គភាពជាតិដែលធ្វើប្រតិភូកម្ម ។

## ៨. និរយោគ (ការឈប់អំពល់ចិត្ត ) ជាអ្វី ?

និរយោគគឺជា វាក្យសព្ទដែលមានដើមកំណើតក្នុងហិរញ្ញកិច្ច និង ធុរៈកិច្ច តែត្រូវបានយកមកប្រើក្នុងបរិបទនៃ រដ្ឋបាលសាធារណៈ ។ និរយោគ កើតមានឡើង នៅពេលណាការទទួលខុសត្រូវ ធ្វើផែនការ និង កិច្ចការរដ្ឋបាល ឬ មុខងារសាធារណៈដទៃៗទៀត ត្រូវបានផ្ទេរពីរដ្ឋាភិបាលទៅស្ថាប័នស្ម័គ្រចិត្តឯកជន ឬ មិនមែនរដ្ឋាភិបាល ។ នេះទាក់ទិនញឹកញាប់ និង ការធ្វើកិច្ចសន្យាចេញ មួយផ្នែកនៃការផ្តល់សេវា ឬមុខងាររដ្ឋបាល និង វិនិយត្តកម្ម (ការឈប់ត្រួតពិនិត្យដោយច្បាប់ )ឬ ឯកជនូបនីយកម្មទាំងស្រុង ។ ជាឧទាហរណ៍ ការផ្តល់ការគាំទ្របច្ចេកទេសទៅថ្នាក់ក្រោមរបស់រដ្ឋាភិបាល ក្នុងផ្នែកធនធានទឹកតាមរយៈក្រុមហ៊ុនឯកជន ជំនួលក្រសួងធនធានទឹកថ្នាក់ជាតិ និង ជាសណ្ឋានមួយនៃនិរយោគ ។

## ៩. គោលការណ៍នៃភាពជាបន្ទាប់នរុំជាអ្វី ?

ភាពជាបន្ទាប់នរុំ គឺជាគោលការណ៍ដែលថ្លែងថា រឿងរ៉ាវទាំងឡាយត្រូវតែលើកយកមកដោះ ស្រាយដោយអាជ្ញាធរមានសមត្ថកិច្ច នៅថ្នាក់ទាបបំផុត ។ តាមធម្មតា គឺត្រូវបានឱ្យនិយមន័យថាជាគំនិតដែលថាអាជ្ញាធរថ្នាក់ជាតិត្រូវតែមានមុខងារបន្តប់នរុំ សំដែងបំពេញតែកិច្ចការណាដែលមិនអាចត្រូវបានសំដែងបំពេញបានដោយមានប្រសិទ្ធភាពនៅថ្នាក់កណ្តាល ឬ នៅមូលដ្ឋាន ។

តាមឧត្តមគតិ ឬ តាម គោលការណ៍ ភាពបន្ទាប់បន្សំគឺជាទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពទាំងឡាយនៃសហព័ន្ធនិយម ។ ទស្សនាទាន ឬ គោលការណ៍នេះត្រូវបានប្រទះឃើញនៅក្នុងរដ្ឋធម្មនុញ្ញជាច្រើននៅជុំវិញពិភពលោក (មើល ជាឧទាហរណ៍ វិសោធន៍កម្មទី៥១០នៃរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក កិច្ចព្រមព្រៀង Maastrichl ឆ្នាំ ១៩៩៣ )។ ឧទាហរណ៍មួយដែលច្បាស់លាស់ជាងគេ ករណីនៃប្រទេសស្វ៊ីសដែលមានរដ្ឋសហព័ន្ធខ្លាំង កសាងឡើងដោយផ្អែលលើគោលការណ៍នៃភាពជាបន្ទាប់បន្សំ ។

គាលការណ៍ទូលំទូលាយនៃភាពជាបន្ទាប់ បន្សំគឺថាបញ្ហាទាំងឡាយគឺត្រូវបានទទួលនូវការដោះស្រាយល្អបំផុតនៅក្នុងអនុប្រព័ន្ធដែលជាកន្លែងដែល បញ្ហាទាំងឡាយនោះកើតឡើង ។ អនុប្រព័ន្ធទាំងឡាយត្រូវបានទទួលការលើកទឹកចិត្តឱ្យដោះស្រាយ ទំនាស់ទាំងឡាយដោយខ្លួនឯងដោយគ្មានយោង បញ្ហា

ទាំងឡាយនេះទៅអាជ្ញាធរថ្នាក់លើ ។ ទោះជា ដំណោះស្រាយណាត្រូវបានអនុម័តក៏ដោយ អនុប្រព័ន្ធ និង ត្រូវតែយកវាទៅធ្វើឱ្យចេញ ។ ដោយហេតុថា ការយល់ព្រមរបស់គេមានសារៈសំខាន់ លក្ខខណ្ឌ ប្រសើរបំផុតនោះគឺ ឱ្យ គេទទួលយកទំនាស់ទាំងឡាយ របស់គេមកដោះស្រាយដោយឯករាជ្យ ។ បើដំនោះស្រាយត្រូវបានធ្វើចេញដោយអនុប្រព័ន្ធនោះការប្តឹង តវ៉ាទៅអាជ្ញាធរនោះគឺគ្មានការចាំបាច់នោះទេ។ ហេតុដូច្នេះគោលការណ៏នៃភាពបន្ទាប់បន្សំអនុវត្តនៅ ក្នុងដែនទាំងឡាយដែលរដ្ឋាភិបាលថ្នាក់ជាតិគ្មានសមត្ថភាពដាច់មុខតែឯង ។ គោលការណ៏នេះកំណត់ ព្រំដែនដែលរដ្ឋាភិបាលត្រូវឬមិនត្រូវប្រព្រឹត្តអំពើ ។ **នេះមានន័យថាទស្សនាទាននៃភាពជាបន្ទាប់បន្សំ មានវិមាត្រតាំងពីច្បាប់ផង និង នយោបាយផង** (Olsen,2007)។

## ១០_ អ្វីជារដ្ឋាភិបាលមូលដ្ឋាន ?

រដ្ឋាភិបាលមូលដ្ឋានគឺជាវាក្យសព្ទឆ័ត្រ ។ យើងមិនសាកល្បងផ្តល់និយមន័យអ្វីមួយទេដោយហេតុថាន័យទាំងឡាយអាចខុសគ្នាយ៉ាងខ្លាំងអាស្រ័យលើផ្នែកពិភពលោកដែលយើងកំពុងដោះស្រាយ ។ ដោយទទួល ដឹងឮពីរឿងនេះ រដ្ឋាភិបាលមូលដ្ឋានអាចមានន័យថា county, ក្រុង, city, town, townthip, អាជ្ញាធរ សាធារណៈមូលដ្ឋាន , school district, អង្គភាពរបស់រដ្ឋាភិបាលតំបន់ឬអន្តររដ្ឋ ឬ ភ្នាក់ងារ ឬ មធ្យោបាយណាមួយរបស់រដ្ឋាភិបាលមូលដ្ឋានទោះបីមាន អនេកគុណនៃអង្គភាពយ៉ាងនេះក៏ដោយក៏វាមានប្រយោជន៏ និង ញែករដ្ឋាភិបាលមូលដ្ឋានចេញជាពីរយ៉ាងទូលំទូលាយ :

- រដ្ឋបាលរដ្ឋនៅមូលដ្ឋាន ដែល គ្រប់គ្រងនិង ធ្វើការងារប្រចាំថ្ងៃ
- អង្គកាយតំណាងនៅមូលដ្ឋាន ដូច ជាក្រុមប្រឹក្សាក្រុងជាដើម ។

អ្វីៗក្រោយគេនេះជាអង្គកាយអភិបាលកិច្ចដែលអាចជ្រើសដោយការបោះ ឆ្នោតផ្ទាល់ ឬ ដោយប្រយោលដូចគ្នានិងករណីនៃរដ្ឋាភិបាលមូលដ្ឋានជាច្រើន ឬ អាចត្រូវបានចាំតាំងដោយ រដ្ឋាភិបាលថ្នាក់លើឬជាតំណាងរបស់សមាគម ។ អាចមានផងដែរនូវសណ្ឋានចម្រុះអង្គកាយអភិបាលកិច្ច ដែលនៅក្នុងនោះតំណាងខ្លះៗត្រូវបានចាត់ហើយខ្លះៗទៀតត្រូវបានជ្រើសរើសដោយការបោះឆ្នោត(EU , 2007) ។

## ១១_ អភិបាលកិច្ចមូលដ្ឋានជាអ្វី?

អភិបាលកិច្ចមូលដ្ឋាន មានរួមបញ្ចូល សំណុំមួយនៃស្ថាប័ន យន្តការ និង តំនើរការ តាមរយៈអ្វីនោះពលរដ្ឋ និង ក្រុមរបស់គេអាចបញ្ចេញយ៉ាងច្បាស់ពីផលប្រយោជន៏ និង សេចក្តីត្រូវការចាំបាច់របស់គេ ដោះស្រាយ

ការទាស់ទែងគ្នា និង ប្រើសិទ្ធ និង កាតព្វកិច្ចរបស់គេនៅមូលដ្ឋាន។ ប៉ុកសម្រាប់សាងសង់ អភិបាលកិច្ច មានច្រើន : ការចូលរួមរបស់ប្រជាពលរដ្ឋ ភាពជាដៃគូរក្នុងចំណោមតួអង្គគន្លឹះនៅថ្នាក់មូលដ្ឋាន សមត្ថភាពនៃតួអង្គនៅមូលដ្ឋាន ឆ្លងកាត់ផ្នែកទាំងអស់ លំហូពហូគុណនៃព័តមាន ស្ថាប័ននៃគណនីភាព និង ការតម្រង់ទិសទៅជួយអ្នកក្រីក្រ(UNDP, 2004)។ អភិបាលកិច្ចនៅមូលដ្ឋានសង្កត់ទៅលើសេចក្តី ត្រូវការចាំបាច់រកមើលផុតពីរទស្សនៈចង្អៀតចង្អល់នៃក្របខណ្ឌការងារច្បាប់ និង អង្គភាពទាំងឡាយ នៃរដ្ឋាភិបាលមូលដ្ឋាន ។ វាស្វែងរកវាប់អនេកគុណនៃទំនាក់ទំនងផ្លូវការ និង ក្រៅផ្លូវការរវាងតួអង្គ ផ្សេងៗក្នុងការអភិវឌ្ឍ(ដូចជា រដ្ឋាភិបាលមូលដ្ឋាន ផ្នែកឯកជន សមាគមទាំងឡាយភ្នាក់ងារសហវិមជ្ឈការ អង្គការសង្គមស៊ីវិល )ដែលធ្វើរូបរាង និង ផ្តល់ឥទ្ធិពលទៅលើផលចំណេញ និង ប្រសិទ្ធភាពនៃប្រព័ន្ធនយោបាយ និង រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ គឺមានកំរិតខ្ពស់នៃថាមពលចំនេញ និង ភាពជិតស្និតរវាងការ គាំទ្រដំនើរការទាំងឡាយនៃអភិបាលកិច្ចថ្នាក់ជាតិ និង អភិបាលកិច្ចមូលដានដោយហេតុថាចំនួនច្រើន នៃទិដ្ឋភាពតាមពិតគឺដូចគ្នា ។ ដូច្នេះហើយចាំបាច់ត្រូវធ្វើការជាមួយគោលការណ៍អភិបាលកិច្ច នៅថ្នាក់មូលដ្ឋានដើម្បីពង្រឹងដំណើរការអភិបាលកិច្ចមូលដ្ឋាន (OLSEN,2007 )។

## ១២. ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានជាអ្វី ?

ការអភិវឌ្ឍ(សេដ្ឋកិច្ច)មូលដ្ឋានជាទស្សនាទានដែលកាន់តែប្រជាប្រិយ ។ ដោយខ្លីវាសំដៅទៅដំនើរការតាមរយៈអ្វី ស្ថាប័នមូលដ្ឋាន និង តួអង្គច្រើនបែបច្រើនយ៉ាងកែល្អ និង ធ្វើការជាមួយគ្នាដើម្បី រៀបចំផែនការ និង អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍមូលដ្ឋានប្រកបដោយចិរភាពនៅក្នុងដែនដីមួយ ។ ការគាំទ្រវិមជ្ឈការអាចត្រូវបានតាមប្រតិបត្ត តាមរយៈកំនែទម្រង់បំពេញបង្គ្រប់សំដៅទៅរកការបង្កើតការផ្សារភ្ជាប់រឹងមាំជាមួយ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និង ការកាត់បន្ថយភាពក្រីក្រ ។

សេចក្តីបំណងសរុបនៃការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន គឺដើម្បីកសាងសមត្ថភាពសេដ្ឋកិច្ច និង ក្របខណ្ឌការងារច្បាប់ធ្វើនិយតកម្ម សម្រាប់តំបន់មូលដ្ឋានមួយ ធ្វើឱ្យអនាគតសេដ្ឋកិច្ច និង គុណភាព នៃជីវិតទាំងអស់គ្នាល្អប្រសើរឡើង ។ គឺជាដំនើការតាមរយៈអ្វីដៃគូទាំងឡាយពីផ្នែកសាធារណ ធុរៈកិច្ច និង មិនមែនរដ្ឋាភិបាលប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកតាមរយៈការសន្ទនា និង សកម្មភាពចូលគ្នា។ ការដាស់តឿនជំរុញឱ្យមានការប្រណាំងប្រជែងសេដ្ឋកិច្ចជាផ្នែកមួយនៃមាិគានេះ ហើយអាចជួយជំរុញការលូតលាស់សេដ្ឋកិច្ច និង បង្កើតការងារធ្វើ។

មានមតិច្រើន សម្រាប់ដាស់តឿនជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដែលមានរួមទាំង បរិយាកាសវិនិយោគធុរៈកិច្ចមូលដ្ឋានល្អប្រសើរ ។ វិនិយោគលើ ហេដ្ឋារចនាសម្ព័ន(ទន់) ទីតាំង និង គ្រឹស្ថានសម្រាប់ធុរៈកិច្ច ។ ការលើកទឹកចិត្តឱ្យមានការលូតលាស់ ធុរៈកិច្ចមូលដ្ឋាន ។ និងការលើក កំពស់ការអភិវឌ្ឍតាមផ្នែក (នឹងចង្កោមធុរៈកិច្ច )ការធ្វើផែនការតំបន់ និង ការជំនួយដល់អ្នកធ្វើការ ដែលមានប្រាក់ចំនូលតិច ឬ ពិបាករកការងារធ្វើ ។ ការកាត់បន្ថយភាពក្រី ក្រសន្ធត់ទុកជាមុនមិនគ្រាន់ តែការអភិវឌ្ឍសេដ្ឋកិច្ចនោះទេប៉ុន្តែសមធ៌មផងដែរ ។ វិមជ្ឈការនាំ មកនូវហានិភ័យនៃភាពខុសគ្នា ក្នុងការអភិវឌ្ឍសេដ្ឋកិច ។ ទាំងនេះត្រូវតែបានទទួលការទូទាត់ដោយប្រើគោលនយោបាយហិរញ្ញវត្ថុត្រឹមត្រូវ (EU , 2007)។

## ១៣_តើវិមជ្ឈការ និង អភិបាលកិច្ចមូលដ្ឋានខុសគ្នាយ៉ាងម្តេច ?

ភាពខុសគ្នាចំបងរវាងវិមជ្ឈការ និង អភិបាលកិច្ចមូលដ្ឋានគឺនៅក្នុងតួអង្គជាក់ស្តែងដែល ចូលរួមក្នុងដំនើរការ និង បែបបទនៃអន្តរកម្មរវាងរដ្ឋាភិបាល ផ្នែក ឥឯកជន និង សង្គមស៊ីវិល ។

វិមជ្ឈការពាក់ពាន់ និង ការកែទម្រង់ និង ដំនើរការនៃស្ថាប័ន និង អង្គការក្នុងផ្នែកសាធារណៈ នឹង ការគាំទ្រដល់ទាំងអស់នោះឯចំនែកអភិបាលកិច្ចមូលដ្ឋានវិញ គឺពាក់ពាន់ច្រើនទៅការគាំទ្រការបង្កើតនូវ បរិស្ថានមួយដែលផ្តល់លទ្ធភាពធ្វើឱ្យងាយស្រួលជួយឱ្យដំនើរការនៃអ្នកពាក់ពាន់ច្រើន...រួមមានផ្នែក សាធារណៈ និង ឯកជនព្រមទាំងសង្គមស៊ីវិលប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដើម្បីជួយដល់ការអភិវឌ្ឍ មូលដ្ឋានឱ្យមានប្រសិទ្ធិភាព។ នេះត្រូវបានសង្ខេបក្នុងតារាងខាងក្រោម ។

| ការកែទម្រង់វិមជ្ឈការ | អភិបាលកិច្ចមូលដ្ឋាន |
|---|---|
| គាំទ្រដល់ធាតុផ្សំនៃការកែទម្រង់វិមជ្ឈការនៅក្នុងផ្នែកសាធារណៈផ្លូវការ | គាំទ្រដល់ការទាក់ទិនទូលំទូលាយនៃពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលផ្នែកឯកជន ក្នុងទំនាក់ទំនងជាមួយធ្វើការជាមួយ និង តាមដានរដ្ឋាភិបាលមូលដ្ឋាន |

| ឧទាហរណ៍មានរួមបញ្ចូលទាំង : | ឧទាហរណ៍មានរួមបញ្ចូលទាំង : |
|---|---|
| ▪ការផ្តល់ជំនួយដល់ក្រសួងថ្នាក់ជាតិដែលទទួលខុសត្រូវអំពីការកែទម្រង់ដើម្បីអភិវឌ្ឍគោលនយោបាយ និង ច្បាប់ថ្មីៗ ។<br>▪កសាងសមត្ថភាពរបស់រដ្ឋាភិបាលមូលដ្ឋានសំរាប់ធ្វើផែនការគ្រប់គ្រងហិរញ្ញវត្ថុ ។ល ។ បានល្អ ។<br>▪ផ្តល់ហិរញ្ញប្បទានសម្រាប់អភិវឌ្ឍដល់រដ្ឋាភិបាលមូលដ្ឋានសម្រាប់ទឹកផ្លូវសុខភាព ។ល ។ | ▪ផ្តល់ជំនួយ ដល់អ្នកម៉ៅការផ្នែកឯកជន ជួយឱ្យគេអាចដេញថ្លៃយកកិច្ចសន្យាការ ងារវិមជ្ឈការ<br>▪អប់រំពលរដ្ឋ និង គាទ្រអង្គការសង្គមស៊ីដើម្បីស្នើទុករដ្ឋាភិបាលមូលដ្ឋាន ថាជំពាក់នូវគណនី<br>▪ផ្តល់ការគាំទ្រដល់សមភាពយ័នឪរ និង ការបង្កាច |

បញ្ហាអភិបាលកិច្ចមូលដ្ឋានអាចត្រូវបានតាមប្រតិបត្តិដោយគ្មានវិមជ្ឈការ ។ ក៏ប៉ុន្តែវិមជ្ឈការនៅពេលដែលបានធ្វើត្រឹមត្រូវ អាចពង្រឹង និង ធ្វើឱ្យដំនើរការមូលដ្ឋានស្របច្បាប់ ។

## ១៤_ គណនីយភាព (ការទទួលខុសត្រូវ )ជាអ្វី ?

គណនីភាព សំដៅទៅការត្រួតពិនិត្យអំណាចប្រើប្រាស់ក្នុងរដ្ឋ និង សង្គម ក៏ដូចទៅកាតព្វកិច្ចសម្រាប់ប្រជាជនទាមទាឱ្យអំណាចពន្យល់ពីសេចក្តីសម្រេចចិត្តរបស់ខ្លួន ។ លើសពីនេះវាយកចិត្តទុកដាក់ និង ករណីកិច្ចត្រួតពិនិត្យភ្នាក់ងារទាំងឡាយដើម្បីផ្តល់រង្វាន់ដល់ការសំដែងបំពេញល្អ ហើយដាក់ទោសការរំលោភអំនាច ។ គណនីភាពសន្មត់ទុកជាមុន ការកំណត់ច្បាស់នៃមុខងារ ករណីកិច្ច និង និយាមសំរាប់វិសាលភាពនៃអំពើស្ថាប័នសាធារណៈ និង ឯកជនទាំងឡាយ ។ ចំពោះវិមជ្ឈការ និង អភិបាលកិច្ចមូលដ្ឋានទំនាក់ទំនងគណនីភាពផ្លាស់ប្តូរហើយបញ្ហាសំខាន់ៗនោះគឺ គណើយភាពឡើងលើ ពីរដ្ឋាភិបាលមូលដ្ឋានទៅថ្នាក់ជាតិ ។ ប៉ុន្តែនៅពេលជាមួយគ្នានោះ គណនីភាពពីលើចុះក្រោមទៅពលរដ្ឋមូលដ្ឋានគឺជាទិដ្ឋភាពសំខាន់ណាស់នៃ អភិបាលកិច្ចដ្ឋាន និង វិមជ្ឈការ ( OLSEN , 2007 ) ។

## ១៥_ តម្លាភាពជាអ្វី?

តម្លាភាពនាំឱ្យឃើញថាសាធារណជនជាទូទៅ ឬ យ៉ាងហោចណាស់អ្នកទ្រទួលការប៉ះពាល់ ដោយផ្ទាល់ត្រូវតែទទួលបាននូវពតិមានពីរដ្ឋ អំពីមូលហេតុនៅក្រោយការសម្រេចចិត្ត លក្ខខណៈវិនិច្ឆ័យ

នៃការធ្វើសេចក្តីសម្រេចចិត ្តរបៀបដែលប្រាថ្នា និង យកទៅអនុវត្តសេចក្តីសម្រេចចិត្ត និង ការមើលឃើញក្នុងចិត្តអ្វីណាអំពីផលទាំងឡាយរបស់វា។ លំហាត់ទាំងឡាយនៃការធ្វើផែនការ និង ការរៀបចំថវិការដោយការចូលរួមលើកកំពស់កំនើនតម្លាភាពនៅថ្នាក់មូលដ្ឋាន ក្នុងការបែងចែកធនធានហើយកំនើនតម្លាភាព អាចត្រូវបានធានាក្នុងការគ្រប់គ្រងមូលនិធិសាធារណៈ (ទាំងប្រាក់ចំនូលទាំងប្រាក់ចំនាយ)តាមរយៈ ការចូលរួម របស់ប្រជាពលរដ្ឋនៅក្នុងគណកម្មាធិការអ្នកប្រើប្រាស់ (សាលារៀន គ្លីនិច សុខភាព អណ្តូងទឹក) [Olsen , 2007] ។

## ១៦. ការចូលរួមជាអ្វី ?

ការចូលរួមនាំឱ្យឃើញថាប្រជាជនគ្រប់ផ្នែកត្រូវការចាំបាច់ឱ្យបានភ្ជាប់ទៅជាមួយដំនើរការ នយោបាយ និង សង្គមដែលមានឥទ្ធិពលទៅលើគេ ។ នេះមានន័យថាមានវេទិការសាធារណៈដែលជាកន្លែង សំរាប់ក្រុមផ្សេងៗអាចបញ្ចេញមតិផ្ទុយពីធម្មតា និង ប្រយោជន៍ផ្ទាល់ខ្លួនហើយជាកន្លែងដែលទស្សនៈ ទាំងនេះត្រូវបានទទួលជាវិភាគទានចំណូលក្នុងដំនើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ។ នៅថ្នាក់រដ្ឋាភិបាល មូលដ្ឋានវិធីសាស្រ្តដែលបានយកមកប្រើពាសពេញជាងគេនោះគឺវិធីធ្វើផែនការ ពីក្រោមទៅលើដែលលើក ទឹកចិត្តឱ្យមានការចូលរួមពាសពេញពីសហគមក្នុងការកំណត់អាទិភាពសំរាប់ការអភិវឌ្ឍមូលដ្ឋាន [Olsen , 2007] ។

## ១៧. តើអ្វីជាតំណភ្ជាប់រវាងវិមជ្ឈការ និង គណនីភាព-តំលាភាព?

វិមជ្ឈការហិរញ្ញវត្ថុរៀបចំឡើងវិញនូវតួនាទី និង ការទទួលខុសត្រូវទាំងឡាយក្នុងនោមថ្នាក់ ផ្សេងៗរបស់រដ្ឋាភិបាលក្នុងបំនងបំពេញអំនាចធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុខ្លះៗ ពីថ្នាក់ជាតិទៅ ថ្នាក់ក្រោមជាតិ ។ និយាមវិមជ្ឈការហិរញ្ញវត្ថុ ធ្វើនិយ័តកម្មក្នុងដែនបួន :

១. ការកំនត់ចំនាយ
២. ការកំនត់ចំនូល
៣. ការផ្ទេរអន្តរដ្ឋាភិបាល
៤. កំចីថ្នាក់ក្រោមរដ្ឋាភិបាល

ស្វ័យភាពចំនាយគឺទៅឆ្ងាយជាងត្រឹមការកំនត់ ការទទួលខុសត្រូវក្នុងការផ្តល់សេវាឱ្យទៅរដ្ឋាភិបាលមូលដ្ឋានទាំងឡាយ...ក្នុងផ្នែកពលរដ្ឋទំហំនៃស្វ័យភាពនេះគឺកំនត់ការពាក់ពាន់នៃរដ្ឋាភិបាលមូលដ្ឋានក្នុងការផ្តល់សេវា។ ស្វ័យភាពប្រាក់ចំនូល និង ប្រព័ន្ធផ្ទេរប្រាក់កំនត់កំរិតមូលនិធិសម្រាប់រដ្ឋាភិបាលមូលដ្ឋានផ្តល់នូវ

សេវាទាំងឡាយនេះ ។

គណនីភាពហិរញ្ញវត្ថុស្វែងរកតំលាភាពក្នុងការគ្រប់គ្រងមូលនិធិសាធារណៈ ។ តម្រូវថារដ្ឋាភិបាលគ្រប់គ្រងហិរញ្ញវត្ថុដោយមានការថ្លឹងថ្លែង និង ធានាភាពសុច្ចរិតក្នុងរបាយការហិរញ្ញវត្ថុ ឬ មិនមែនហិរញ្ញវត្ថុ ការត្រួតពិនិត្យ ធ្វើថវិការ និង ប្រព័ន្ធវាយតំលៃការសំដែងបំពេញតួនាទីភារកិច្ច ។ វាក៏តម្រូវឱ្យរាយការណ៍ដោយអាចយល់បានអំពីអ្វីដែលរដ្ឋាភិបាលមូលដ្ឋានបានសំរេចជាមួយ និង ចំនាយទាំងឡាយរបស់ គេ ។

វិធានការទាំងឡាយពីជ្រុងផ្តល់ដើម្បីធ្វើឱ្យគណនីភាពហិរញ្ញវត្ថុពីលើចុះក្រោម និង ពីក្រោម ឡើងលើបានល្អប្រសើរមានរាប់បញ្ចូលសមត្ថភាពរឹងមាំសម្រាប់ធ្វើថវិការ និង គ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ។ ស្តង់ដារ( បទដ្ឋាន )សំរាប់ត្រួតពិនិត្យការផ្ទេរប្រាក់ចំនូលអន្តររដ្ឋាភិបាល (គឺរបាយការណ៏ សវនកម្មល្អស្អាត ការដាក់ជូននូវសេចក្តីថ្លែងការហិរញ្ញវត្ថុ) ។ ការបោះពុម្ពតួលេខដែលបានផ្ទេរ។ ប្រព័ន្ធសវនកម្មសាធារណមូលដ្ឋានថ្លា...ព្រមទាំងគំហើញសវនកម្មដែលមានជាសាធារណៈ ។ និយាម ច្បាស់ៗ សម្រាប់កំចីដោយមានការទទួលខុសត្រូវនៅមូលដ្ឋាន (រួមទាំងនិយាមអំពីការខកខាន មិនបានសង) ។ ព្រមទាំងការចូលមើលបានជាសាធារណៈនូវព័តមានអំពីកំចី ។ និង និយាមទាំងឡាយ កំនត់ ច្បាស់លាស់អំពីកំហិតរឹងនៃថវិការសម្រាប់រដ្ឋាភិបាលមូលដ្ឋាន។

វិធានការទាំងឡាយពីជ្រុងសេចក្តិត្រូវការ សម្រាប់គណនីភាពហិរញ្ញវត្ថុរួមមានព័តមានហិរញ្ញវត្ថុរបស់រដ្ឋាភិបាលមូលដ្ឋានដែលអាចចូលមើលបាន ជាសាធារណ (មានរួមទាំងថវិការ សេចក្តីថ្លែងការហិរញ្ញវត្ថុចុងឆ្នាំ) ។ ការចូលរួមយ៉ាងរឹងមាំ ពីសាធារណជនក្នុងដំនើថវិការតាមរយៈការប្រតិបត្តទាំងឡាយនៃការធ្វើថវិការដោយចូលរួមការ ធ្វើផែនការថវិការ និង ការបែងចែកធនធានដោយមានការរព្ញកដឹងពីយែនឌ័រ ពង្រឹងដោយសវនកម្មយែនឌ័រ ។ ការវិភាគថវិការឯករាជ្យ ។ កម្មវិធីតាមដានការអនុវត្តថវិការ និង ល្បែច( ការលេច) ។ មូលនិធិទាំង ឡាយ ។

**គណនីនយោបាយ** គឺជាដំនើការ តាមអ្វីពលរដ្ឋប្រកាន់ទុកមន្ត្រីជាប់ឆ្នោតរបស់គេថាជំពាក់គណនីអំពីសិរិយាបថ និង ការសំដែងបំពេញរបស់ខ្លួន ។ នេះអាចធ្វើជាឧទាហរណ៏ដោយផ្ទាល់តាមរយៈការ បោះឆ្នោត ។ គណនីភាពនយោបាយអាចត្រូវបានធ្វើឱ្យល្អប្រសើរឡើងតាមមន្ត្រីជាប់ឆ្នោតមូនដ្ឋាន មើលពីលើ មន្ត្រីផ្នែកប្រតិបត្តិមូលដ្ឋាន តាមរយៈសកម្មភាព ដែលបង្កើតនូវសតិរព្ញកដឹងអំពីការសំដែងបំពេញ នៃគោលនយោបាយរបស់រដ្ឋាភិបាល មូលដ្ឋាន និង តាមរយៈការចូលទាក់ទិនផ្ទាល់របស់ពលរដ្ឋ ក្នុងការធ្វើការសម្រេចចិត្តហួសពីការបោះឆ្នោត ។

## សណ្ឋាននៃវិមជ្ឈការ និង គណនេយ្យភាព ៖

| ការសំរេចចិត្ត | | អ្នកធ្វើសេចក្តីសម្រេចចិត្តឈរនៅ | |
|---|---|---|---|
| | | **ថ្នាក់ជាតិ** | **ថ្នាក់មូលដ្ឋាន** |
| អ្នកធ្វើសេចក្តីសម្រេចចិត្តជាក់តំណាងនយោបាយទៅ | អង្គភាពថ្នាក់ជាតិ | **មជ្ឈការ**<br>ទីបញ្ជាប់ការនៃក្រសួងសុខាភិបាលនៅថ្នាក់ជាតិលាតពង្រាយបុគ្គលិកសុខភាពក្នុងចំនោមអង្គភាពរដ្ឋបាលផ្សេងៗក្នុងប្រទេស ។<br>**ប្រតិភូកម្ម**<br>ក្រុមប្រឹក្សាភិបាលសុខភាពថ្នាក់ជាតិ ឬ គណៈកម្មការសេវាសុខភាព ។<br>ស្វ័យត្តតាមប្រៀបធៀបគ្រប់គ្រងការលាតពង្រាយបុគ្គលិកពេញប្រទេសជាតិ ក៏ជាភ្នាក់ងារប្រតិបត្តដែលបានទទួលអំណោយដែលត្រូវបានធ្វើប្រតិកម្មភូ ចំនុះក្រសួង ។ | **សហវិមជ្ឈការ**<br>មន្ត្រីប្រតិបត្តការសុខភាពបានទទួលឆន្ទានុសិទ្ធពីទីបញ្ជាការទាក់ទង និង ការកំនត់ចែកការទទួលខុសត្រូវ និង ស្ថានីករណីកិច្ចឱ្យសមាជិកបុគ្គលិកក្រោមឱវាទ ។ |
| | អង្គភាពមូលដ្ឋាន និងពហុជន | **ប្រតិភូកម្មជាមួយការចូលរួម**<br>ក្រុមប្រឹក្សាភិបាលសុខភាព ឬ គណកម្មាធិការសេវាសុខភាពស្វ័យត្តដោយប្រៀបធៀបគ្រប់គ្រងការលាតពង្រាយបុគ្គលិកនៅមូលដ្ឋាន | **ការផ្ទេរអំណាចមកក្រោម**<br>រដ្ឋាភិបាលមូលដ្ឋានដែលត្រូវបានជាប់ឆ្នោតត្រូវបានប្រគល់ការទទួលខុសត្រូវសម្រាប់ការជ្រើសឱ្យចូលបំរើការ ការលាតពង្រាយ និង ការសង្រ្កៀនវិន័យបុគ្គលិកសុខភាពមូលដ្ឋាន (បន្ថែមលើបុគ្គលិកទាក់ទិន និង ផ្នែកដទៃទៀត) ។<br>ការចូលរួមនៃអ្នកប្រើប្រាស់...គណកម្មាធិការសុខភាពមួយបង្កើតឡើងនូវគ្លីនិចមូលដ្ឋានត្រូវបានប្រគល់ការទទួលខុសត្រូវសម្រាប់គ្រប់គ្រងគ្លីនិក ដោយមានរួមទាំងឆន្ទានិសិទ្ធខ្លះក្នុងការជ្រើសរើសបុគ្គលិកគាំទ្រឱ្យចូលបំរើការ និង ទិដ្ឋភាពខ្លះៗនៃសុខុមាលភាព នៃបុគ្គលិកទូទៅ ។ |

ឆាកនយោបាយមូលដ្ឋានសមស្របមួយដែលមានអំណោយផលល្អដល់គណនីភាពពីលើចុះក្រោមតម្រូវឱ្យ

មានការបោះឆ្នោតដោយសេរី នឹង ត្រឹមត្រូវ និង ការប្រណាំប្រជែងនយោបាយសម្រាប់អភិបាល និង សមាជិកក្រុមប្រឹក្សាភិបាល ។ ឆាកនយោបាយបែបនេះក៏គាំទ្រប្រព័ន្ធប្រណាំប្រជែង ពហុបក្សផងដែរ ហើយកផ្តល់នូវការបែងចែកអំនាចច្បាស់រវាងអង្គកាយប្រតិបត្ត (គឺអភិបាលមូលដ្ឋាន) និងអង្គកាយ និតិប្រតិបត្ត (គឺក្រុមប្រឹក្សាភិបាល) នៃរដ្ឋាភិបាលមូលដ្ឋាន។ វាក៏ស្ថាបនានូវយន្តការនិងផ្តល់នូវ ឧបករណ៍ទៅអង្គកាយ និតិបញ្ញត្តិ នៅក្នុងការមើលពីលើការប្រតិបត្តការនៃ អង្គកាយនិតិប្រតិបត្ត ។

ដើម្បីធ្វើឱ្យយុទ្ធសាស្ត្រអភិបាលកិច្ចមូលដ្ឋាន នៅក្នុងកគណនីភាពរូបីជាក់ស្តែងគឺមានដែនគន្លឹះបួន ដែលត្រូវផ្តោតលើ :

ក).ទំនាក់ទំនងទាំងឡាយរវាងតួអង្គ អំណាច និង គណនីភាព (ការស្រាវជ្រាវអំពីផលប៉ះពាល់ នៃបរិស្ថាននយោបាយមូលដ្ឋានទៅលើផលចេញ នៃកំនែទម្រង់វិមជ្ឈការ ) ។

ខ). វិសមភាពសេដ្ឋកិច្ច និង សង្គមទាំងឡាយ (ដើម្បីអោយបានយល់កាន់តែល្អប្រសើរឡើង អំពីទំនាក់ទំនង រវាងវិសមភាពសេដ្ឋកិច្ច និង "ការចាប់បានរបស់វិរៈជន " ដោយសារ គេអាចមានឥទ្ធិពលទៅលើការច្នៃប្រឌិតនៃកំណែទម្រង់វិមជ្ឈការ) ។

គ). រចនាសព្ព័ន្ធមូលដ្ឋាន និង ប្រព័ន្ធគណបក្ស (ដើម្បីក្តាប់បាននូវរចនាសម្ព័ន្ធនៃ ប្រព័ន្ធដំណើរការ បោះឆ្នោតនៃរដ្ឋាភិបាលមូលដ្ឋានព្រមទាំងការប៉ះពាល់របស់វាទៅលើក៏រិតនៃគណនីភាពនៃរដ្ឋាភិបាល មូលដ្ឋានចំពោះពលរដ្ឋ ) ។

ឃ). កត្តាបំបរគណនីភាព និង ការសំដែងបំពេញនៃអ្នកដឹកនាំជាប់ឆ្នោតមូលដ្ឋាន ដើម្បីពិនិត្យ មើលកត្តាដែលបរការសំដែងបំពេញអ្នកដឹកនាំជាប់ឆ្នោតមូលដ្ឋាន ដោយមានរាប់បញ្ចូលទាំង គណនីភាពផងដែរ ) ។

ក៏ប៉ុន្តែហានិភ័យនៃការប្រើមូលនិធិទាំងឡាយមិនចំមុខសញ្ញា ឬ អំពើពុករលួយគឺឃើញជាក់ស្តែង ដោយសារមូលនិធិ និង អំណាចបន្ថែមច្រើនទៀតត្រូវបានផ្ទេរ មកក្រោមឱ្យទៅភាពនៃការដឹកនាំថ្មី នឹង ដែលមិនទាន់ទទួលការបណ្តុះបណ្តាល និង ឱ្យទៅរដ្ឋបាល មូលដ្ឋានដែលសមត្ថភាពនៅមានក៏រិត សម្រាប់ ដូចជាការគ្រប់គ្រងហិរញ្ញវត្ថុ។ បើមានមូនិធិបន្ថែម កាន់តែច្រើនត្រូវបានបង្ហូរឆ្ពោះទៅរដ្ឋាភិបាលមូលដ្ឋាន តាមរយៈការគាំទ្រសេដ្ឋកិច្ចទូទៅ និង តាមកម្មវិធី គាំទ្រ តាមផ្នែកហានិភ័យនៃវិមជ្ឈការនៃអំពើពុករលួយ ក៏ពិតជាមាននៅសម្ងំផងដែរថ្វីត្បិតតែ វាអាចត្រូវ បផ្លើស ។ ថ្វីត្បិតតែមូលនិធិដែលត្រូវបានដកយក មិនត្រូវមុខសញ្ញា អាចមានតិចកត់សំគាល់មិនបាន បើប្រៀបធៀបទៅនិង ការប្រើមិនចំមុខសញ្ញា យ៉ាងធំជាងនៅថ្នាក់ជាតិ ។ ឧទាហរណ៍នៃការដកយកចេញច្រើនហួសការផ្តល់ទុកដែលមានក៏រិត ពីគណនីណាមួយ

ឬ ការលួចត្រង់ៗ ពីហិបប្រាក់នៃរដ្ឋាភិបាលមូលដ្ឋានជាញឹកញាប់ គឺត្រូវបានមើលឃើញច្បាស់ចំពោះសាធារណៈជន ទូទៅជាងការចែកចំណេញ ឬបោកបន្លំនៅថ្នាក់ក្រសួង ។ ករណីបែបនេះ គឺត្រូវបានយកមកប្រើដោយ ស្រួលក្នុងការពិភាក្សាតទល់...ជាពិសេសពីក្រសួងបច្ចេកទេស-ដើម្បីផ្តល់សារធាតុដល់សេចក្តីត្រូវ ការចាំបាច់ឱ្យមានការត្រួតពិនិត្យសកម្មភាពមូលដ្ឋានពីថ្នាក់ជាតិថ្វីត្បិតតែវាអាចត្រូវបានបកស្រាយថាជាសាក្ខីភាពនៃការបំរើការងារល្អមួយនៃការតាមដានជាសាធារណៈមើលរដ្ឋាភិបាលនៃរដ្ឋាភិបាលមូលដ្ឋាន ។ ហេតុនេះហើយបានជាត្រូវតែសង្កត់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុទូទៅ របស់រដ្ឋាភិបាល និង រដ្ឋបាលមូលដ្ឋាន និង កែលំអគុណភាពនៃគណនីភាពហិរញ្ញ និង សវនកម្មគឺ និងដោយ មិនផ្តោតសមត្ថភាពតាមផ្នែកដាច់ៗពីគ្នា( Olsen , 2007) ។

## ១៨. តើអ្វីទៅជាតំណភ្ជាប់រវាងវិមជ្ឈការ និង សង្គមស៊ីវិល ?

ក៏ប៉ុន្តែ បទពិសោធន៍ពាសពេញពិភពលោកចង្អុលទៅភាពពិតដែលថា វិមជ្ឈការតាមធម្មតាមានន័យថាសហវិមជ្ឈការ ឬ ការផ្ទេរមកក្រោមនូវអំនាច និង អាជ្ញាពីរដ្ឋាភិបាលថ្នាក់ជាតិ មកឱ្យអាជ្ញាធរ ក្រោមជាតិទោះបីគេជារដ្ឋបាលខេត្តឬ ស្រុកក្នុងទីប្រជុំជនក្រុមព្រឹក្សាភិបាលមូលដ្ឋានជនបទ អាជ្ញាធរ "ខោនទី " ។ល។ ក៏ដោយ ។ នៅក្នុងច្រើនករណីវិមជ្ឈការឈប់នៅត្រឹមថ្នាក់ ហើយកម្រឃើញណាស់ ដែលរដ្ឋាភិបាលទទួលស្គាល់ថាស្ថាប័នសង្គមស៊ីវិល ប្រជាជនសាមញ្ញអាចរងទុក្ខពីមជ្ឈការអំណាចនៅថ្នាក់ ក្រោមជាតិក៏ដូចជាគេទទួល រងទុក្ខ នៅថ្នាក់ក្រោមបញ្ជារដ្ឋាភិបាលថ្នាក់ជាតិក្នុងប្រទេស ។ ដោយការទទួលស្គាល់ នេះ ការប្រឈមប្រជែងចំបងសព្វថ្ងៃក្នុង ការពិភាក្សាអំពីអភិបាលកិច្ចមូលដ្ឋាន គឺធានាអោយប្រាកដថា ការពង្រឹងរដ្ឋាភិបាលមូលដ្ឋានតាមរយៈវិមជ្ឈការធ្វើដំណើរស៊ីសង្វាក់គ្នា និង ការប្រឹងប្រែងដោយប្រុងប្រយ័ត្ន ដើម្បីកែលម្អ និង ពង្រឹងរចនាសម្ព័ន្ធដំណើរការ និង ស្ថាប័នសង្គមស៊ីវិល នៅថ្នាក់ក្រោមជាតិតាមបែបដែលនិង បណ្តោយឱ្យទំនាក់ទំនងរបស់គេជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ មានលក្ខណៈអន្តរកម្ម និង ពង្រឹងគ្នាទៅវិញទៅមក ។

ការប្រឈមប្រជែងដែលទាក់ទងផងដែរក្នុងការ បង្អាចសង្គមស៊ីវិលនោះទាក់ទងនិងវិសាលភាពដែលបរិស្ថាននយោបាយត្រូវបានទទួលដឹងថាបានផ្តល់ការគាំទ្រដល់សុខុមាលភាព ប្រជាជន ។ ដើម្បីឱ្យសង្គមស៊ីវិលមានតួនាទី បរិស្ថានសង្គម ស្ថាប័នា និងគាលនយោបាយដែលផ្តល់ការគាំទ្រ មួយត្រូវតែបានបង្កើតឡើងដោយសារថានេះតាមធម្មតាគឺត្រូវបានត្រូវការដើម្បីការអភិវឌ្ឍ សេចក្តីទុកចិត្ត សង្គមមួយដែលមានចិរភាពហើយដែលជាមូលដ្ឋានចាំបាច់មួយសម្រាប់ការចូលរួមខ្ជាប់ខ្ជួននៃសង្គមស៊ីវិលក្នុងបញ្ហាអន្តរាគមន៍សុខុមាលភាពសង្គម ។ ក្នុងករណីទីដែលគ្មានប្រព័ន្ធថា ដែលមានគណនីភាព និង ត្រឹមត្រូវ សម្រាប់

ចែករំលែកធនធាន កាលានុបវត្តភាពក្នុងចំណោមប្រជាពលរដ្ឋ (ជាឧទាហរណ៍ កាលានុបវត្តភាពមានការងារធ្វើដែលធានាស្តង់ដារស់នៅអប្បរមា )សមាជិកក្រីក្រជាងគេក្នុងសង្គម ក្លាយទៅជាជាប់រវល់ខ្លាំងជាមួយ និង បញ្ហាសេដ្ឋកិច្ចសម្រាប់ការរស់រានមានជីវិត ជាជាងជាមួយ និង ទ្រព្យល្អរួម ការស្វែងប្រតិបត្តរកអ្វីល្អជាងនោះ ។ គឺមានតម្រូវការដើម្បីកសាងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ដែលស៊ីសង្វាក់គ្នា និងស្ថានភាព ហើយបែបយ៉ាងនៃការគាំទ្រ (ការប្រតិបត្តល្អបំផុត ) និង អាស្រ័យផងដែរទៅលើស្ថានភាព។ គឺមានតម្រូវការថែមទៀតដែលត្រូវតែទទួលស្គាល់ថាការកែទម្រង់ វិមជ្ឈការទាំងឡាយ ផ្តល់នូវកាលានុបវត្តភាពដើម្បីចូលរួមក្នុងការកសាងផ្នែកសាធារណៈដែលឆ្លើយតប- ទាំងនៅថ្នាក់ជាតិទាំងនៅថ្នាក់ក្រោមជាតិ ក៏ប៉ុន្តែដោយសារថានេះជាដំណើរការ ការសង្គម និង នយោបាយវាមិនអាចត្រូវដោះស្រាយ បានដោយដំណោះស្រាយបច្ចេកទេសតែឯកឯង (Olsen, 2007 ) ។